សុវត្ថិភាពនៅកន្លែងការងារ

# The 12 Golden Rules



TotalEnergies

FOR ME, FOR YOU, FOR ALL
SAFETY
TotalEnergies

# វិចារណកថា

**សុវត្ថិភាពជាគុណតម្លៃស្នូលនៅក្នុងក្រុមហ៊ុន។ វាជាមូលដ្ឋានគ្រឹះនៃឧត្តមភាពប្រតិបត្តិការនៅក្នុងគ្រប់ផ្នែកអាជីវកម្មទាំងអស់របស់យើង។**

រួមគ្នា ក្នុងនាមជាបុគ្គលិកក្រុមហ៊ុន TotalEnergies និងក្រុមហ៊ុនដៃគូ យើងនាំគ្នាប្តេជ្ញាចិត្តរៀងៗខ្លួន និងរួមគ្នាក្នុងការធានានូវសុវត្ថិភាពជារៀងរាល់ថ្ងៃនៅក្នុងប្រតិបត្តិការរបស់យើង និងនៅទីកន្លែងរបស់យើង ដោយមានគោលដៅរួម៖ "គ្មានគ្រោះថ្នាក់ដល់ជីវិត"

**Golden Rules របស់យើងដែលបានបង្កើតឡើងផ្អែកលើមូលដ្ឋាននៃមេរៀនដែលទទួលបាន គឺមានសារៈសំខាន់ក្នុងការសម្រេចបាននូវគោលបំណងរបស់យើងពាក់ព័ន្ធនឹងសុវត្ថិភាព។** ដោយទទួលយកម្ចាស់ការ និងអនុវត្តដោយមានការប្រុងប្រយ័ត្នជាប្រចាំសម្រាប់ទាំងខ្លួនឯងផ្ទាល់ និងបុគ្គលិករួមការងាររបស់យើង Golden Rules ទាំងនេះនឹងសម្រេចបាននូវគោលដៅរបស់ខ្លួននិងត្រូវបានអនុវត្តនៅក្នុងសកម្មភាពរាល់ថ្ងៃរបស់យើង។

ខ្ញុំជឿជាក់ថា គ្រោះថ្នាក់ទាំងអស់អាចការពារបាន!

**ការប្តេជ្ញាចិត្តរបស់អ្នកគ្រប់គ្នា**ក្នុងការអនុវត្តជាប្រព័ន្ធនូវ Golden Rules ទាំងនេះ គ្រប់ទីកន្លែង រៀងរាល់ថ្ងៃ គឺស្របនឹងគោលដៅរបស់ក្រុមហ៊ុន៖ ដាក់ការអភិវឌ្ឍជាចីរភាពឱ្យនៅចំកណ្តាលបេះដូងនៃយុទ្ធសាស្រ្ត គម្រោង និងប្រតិបត្តិការរបស់យើង។

**មីឆែល ផាតុន**

**អនុប្រធានជាន់ខ្ពស់ផ្នែក សុខភាព សុវត្ថិភាព និងបរិស្ថាន**

# សុវត្ថិភាព

## សម្រាប់ខ្ញុំ សម្រាប់អ្នក សម្រាប់អ្នកទាំងអស់គ្នា

ដើម្បីធ្វើការងារប្រកបដោយសុវត្ថិភាព និងការពារអាយុជីវិតទាំងអស់គ្នា យើងត្រូវតែ៖

- ទទួលយក និងអនុវត្ត Golden Rules គ្រប់ពេលវេលា
- អន្តរាគមន៍ប្រសិនបើយើងអង្កេតឃើញនូវគម្លាតចេញពីGolden Rules របស់យើង
- រាយការណ៍ពីភាពមិនប្រក្រតីដើម្បីរៀនមេរៀនពីវា
- ចែករំលែកការអនុវត្តល្អៗអំពីការប្រើប្រាស់Golden Rules

## Golden Rules ទាំង ១២ របស់យើង

1 | ស្ថានភាពប្រកបដោយគ្រោះថ្នាក់ខ្ពស់

2 | ចរាចរណ៍

3 | ចលនាបម្លាស់ទីរាងកាយ និង ឧបករណ៍ប្រើដោយដៃ

4 | សម្ភារការពារខ្លួន

5 | លិខិតអនុញ្ញាតការងារ

6 | ប្រតិបត្តិការលើកស្ទូច

7 | ការងារលើប្រព័ន្ធថាមពល

8 | ទីកន្លែងបិទជិត

9 | ការងារជីកកាយ

10 | ការងារនៅទីខ្ពស់

11 | ការងារក្តៅ

12 | គន្លងគ្រោះថ្នាក់

## Rule 1

# ស្ថានភាពប្រកបដោយគ្រោះថ្នាក់ខ្ពស់

ខ្ញុំចៀសវាងស្ថានភាពគ្រោះថ្នាក់ខ្ពស់

ការប្តេជ្ញាចិត្តរបស់ខ្ញុំដើម្បីសុវត្ថិភាព៖

- **ខ្ញុំមិនជក់បារីឬបារីអេឡិចត្រូនិក**នៅខាងក្រៅកន្លែងកំណត់
- **ខ្ញុំមិនធ្វើការឬបើកបរ**ក្រោមឥទ្ធិពលគ្រឿងស្រវឹង ឬថ្នាំញៀន
- **ខ្ញុំយល់ពី**ស្ថានភាពមិនប្រក្រតី និង**រាយការណ៍**ទៅអ្នកគ្រប់គ្រងរបស់ខ្ញុំ
- **ខ្ញុំដឹងពី**ហានិភ័យមុនរាល់ពេលអនុវត្តប្រតិបត្តិការងារដែលមិនប្រចាំ ឬស្មុគស្មាញ
- **ខ្ញុំគោរពតាម**ការណែនាំប្រតិបត្តិការសម្រាប់បិទ និងបើកដំណើរការឧបករណ៍ និងម៉ាស៊ីន។

## Rule 2

# ចរាចរណ៍

អនុវត្តតាមវិធានសុវត្ថិភាពនៅពេលបើកបរ ជិះកង់ ឬដើរ

ការប្តេជ្ញាចិត្តរបស់ខ្ញុំដើម្បីសុវត្ថិភាព៖

- **ខ្ញុំពិនិត្យ**លក្ខខណ្ឌយានជំនិះមុនពេលប្រើប្រាស់
- **ខ្ញុំតែងតែ**ពាក់ខ្សែក្រវ៉ាត់ជានិច្ច
- **ខ្ញុំមិនបើកបរលើស**ល្បឿនកំណត់ និងសម្របការបើកបរតាមលក្ខខណ្ឌផ្លូវ
- **ខ្ញុំមិនប្រើ**ប្រព័ន្ធទំនាក់ទំនងនៅពេលបើកបរ ដូចជា ទូរស័ព្ទ អាយកូម វិទ្យុទំនាក់ទំនង និងសូម្បីតែកាសពាក់ត្រចៀក
- **ខ្ញុំគោរព**ពេលវេលាបើកបរដែលអនុញ្ញាត និងគម្រោងក្នុងការធ្វើដំណើរ
- **ខ្ញុំប្រើ**ផ្លូវដែលកំណត់សម្រាប់ថ្មើរជើង និងអ្នកជិះកង់
- **ខ្ញុំប្រើប្រាស់**បង្កាន់ដៃនៅពេលប្រើជណ្តើរ។

## Rule 3

# ចលនាបម្លាស់ទីរាងកាយ និង ឧបករណ៍ប្រើដោយដៃ



ខ្ញុំប្រើប្រាស់សម្ភារឱ្យមានសុវត្ថិភាព

ការប្ដេជ្ញាចិត្តរបស់ខ្ញុំដើម្បីសុវត្ថិភាព៖

- **ខ្ញុំពិនិត្យ**ថា សម្ភាររបស់ខ្ញុំគឺ៖
  - ជាសម្ភារដែលបញ្ជាក់នៅក្នុងលិខិតអនុញ្ញាតការងារ ឬការណែនាំប្រតិបត្តិការ
  - ស័ក្តិសមសម្រាប់ការងារ និងកន្លែងការងារ
  - មានលក្ខណៈល្អ
- **ខ្ញុំប្រើ**ប្រាស់សម្ភារនានា រួមទាំងសម្ភារសម្រាប់ធ្វើតេស្តសម្ពាធ ស្របតាមកម្រិតស្តង់ដាដាក់លាក់របស់រោងចក្រផលិត
- **ខ្ញុំដាក់ទីតាំង**រាងកាយរបស់ខ្ញុំឱ្យកាត់បន្ថយភាពតានតឹងខ្លាំងពេក។

## Rule 4

# សម្ភារការពារខ្លួន(PPE)



ខ្ញុំចាំបាច់ត្រូវពាក់សម្ភារការពារខ្លួន

ការប្ដេជ្ញាចិត្តរបស់ខ្ញុំដើម្បីសុវត្ថិភាព៖

- **ខ្ញុំពិនិត្យ**ថា សម្ភារការពារខ្លួនរបស់ខ្ញុំមានលក្ខណៈល្អមុនពេលប្រើប្រាស់
- **ខ្ញុំពាក់**មួកការពារដែលមានខ្សែរឹតបណ្ដឹងនឹងចង្ការ
- **ខ្ញុំពាក់**សម្ភារការពារខ្លួនដែលត្រូវនឹងការងារ និងកន្លែងដែលខ្ញុំកំពុងធ្វើការ
- **ខ្ញុំពាក់**អាវពោងនៅពេលណាដែលចាំបាច់។

Rule 5

# លិខិតអនុញ្ញាតការងារ

ខ្ញុំធ្វើការដោយមានលិខិតអនុញ្ញាតការងារ

ខ្ញុំប្តេជ្ញាចិត្តដើម្បីសុវត្ថិភាព៖

- ☑ **ខ្ញុំបានពិនិត្យ**លិខិតអនុញ្ញាត និងវិញ្ញាបនបត្រពាក់ព័ន្ធនានា
- ☑ **ខ្ញុំមានសមត្ថភាព និងត្រូវបានផ្តល់សិទ្ធិ**ឱ្យធ្វើការងារនេះ
- ☑ **ខ្ញុំយល់**ពីលិខិតអនុញ្ញាតការងារ
- ☑ **ខ្ញុំធានាថា**បានកំណត់ចំណុចត្រូវអន្តរាគមន៍
- ☑ **ខ្ញុំបានពិនិត្យថា** បានបំពេញតាមលក្ខណៈសុវត្ថិភាពក្នុងការចាប់ផ្តើមការងារ
- ☑ **ខ្ញុំឈប់** និងវាយតម្លៃឡើងវិញនូវហានិភ័យ ប្រសិនបើមានលក្ខខណ្ឌផ្លាស់ប្តូរ និងរាយការណ៍ទៅអ្នកគ្រប់គ្រងរបស់ខ្ញុំ។

Rule 6

# ប្រតិបត្តិការលើកស្ទូច

ខ្ញុំអនុវត្តតាមគម្រោងលើកដាក់

ខ្ញុំប្តេជ្ញាចិត្តដើម្បីសុវត្ថិភាព៖

- ☑ **ខ្ញុំបង្កើតរបាំងបាំង** និងកំនត់តំបន់ហាមឃាត់
- ☑ **ខ្ញុំបានពិនិត្យថា** ឧបករណ៍លើកស្ទួចត្រូវបានត្រួតពិនិត្យ មានលក្ខណៈល្អ និងត្រូវនឹងគោលបំណង
- ☑ **ខ្ញុំប្រតិបត្តិការ**តែឧបករណ៍ដែលខ្ញុំមានសមត្ថភាពប្រើប្រាស់
- ☑ **ខ្ញុំពិនិត្យថា** បន្ទុកត្រូវបានគ្រប់គ្រងយ៉ាងសុវត្ថិភាព ហើយខ្ញុំគ្រប់គ្រងបន្ទុកនៅពេលធ្វើចលនា
- ☑ **ខ្ញុំធានាថា** មានវត្តមានអ្នកគ្រប់គ្រងប្រតិបត្តិការដែលមានសមត្ថភាព សម្រាប់ប្រតិបត្តិការលើកស្ទួច
- ☑ **ខ្ញុំមិនត្រូវ**ដាក់ទីតាំងខ្លួនរបស់ខ្ញុំក្រោមបន្ទុកដែលត្រូវព្យួរនោះទេ។

## Rule 7

# ការងារលើប្រព័ន្ធថាមពល



ខ្ញុំពិនិត្យការចម្លង និងអវត្តមានថាមពល និងចរន្ត មុនពេលអន្តរាគមន៍

ខ្ញុំប្តេជ្ញាចិត្តដើម្បីសុវត្ថិភាព៖

- **ខ្ញុំមាន**លិខិតអនុញ្ញាតធ្វើការងារ និងវិញ្ញាបនបត្រលើផ្នែកប្រព័ន្ធថាមពល
- **ខ្ញុំបានដឹង**ពីប្រភពថាមពល និងចរន្តទាំងអស់
- **ខ្ញុំគោរពផែនការ**នៃការផ្តាច់ថាមពល
- **ខ្ញុំបញ្ជាក់ថា** ប្រភពថាមពល និងប្រេងត្រូវបានផ្តាច់ ចាក់សោ និងដាក់ស្លាក
- **ខ្ញុំធានាថា**មិនមានការផ្គត់ផ្គង់ថាមពល និងចរន្ត
- **ខ្ញុំធានាថា** មិនមានសេសសល់ ឬផ្ទុកថាមពល និងចរន្តបង្ករ
- **ខ្ញុំធានាថា** ការងារបានបញ្ចប់ និងពិនិត្យការផ្តាច់នូវភាពចម្លងថាមពលមុនពេលចាប់ផ្តើម។

## Rule 8

# ទីកន្លែងបិទជិត



ខ្ញុំទទួលបានការអនុញ្ញាតមុនពេលចូលកន្លែងបិទជិត

ខ្ញុំប្តេជ្ញាចិត្តដើម្បីសុវត្ថិភាព៖

- **ខ្ញុំមាន**លិខិតអនុញ្ញាតធ្វើការងារ និងវិញ្ញាបនបត្រចូលកន្លែងបិទជិត
- **ខ្ញុំធានាថា** ប្រភពថាមពល និងចរន្តត្រូវបានដកចេញ
- **ខ្ញុំពិនិត្យ** និងប្រើប្រាស់ឧបករណ៍ការពារដង្ហើមនៅពេលចាំបាច់
- **ខ្ញុំបញ្ជាក់ថា**មានផែនការសង្គ្រោះ នៅពេលមានគ្រោះថ្នាក់
- **ខ្ញុំបញ្ជាក់ថា** សារធាតុនៅក្នុងបរិយាកាសត្រូវបានធ្វើតេស្តមុនពេលចូលធ្វើការ និងត្រូវតាមដានគ្រប់សារធាតុទាំងនៅឲ្យបានទៀងទាត់
- **ខ្ញុំបញ្ជាក់ថា** មានការត្រួតពិនិត្យសម្រាប់ការចូល/ចេញ និងសម្រាប់ការផ្តល់សញ្ញាឱ្យប្រុងប្រយ័ត្ន
- **ខ្ញុំទទួល**បានការអនុញ្ញាតឱ្យចូល។

Rule **9**

# ការងារជីកកាយ



ខ្ញុំធានាសុវត្ថិភាពទីកន្លែង
ការងារជីកកាយ

ខ្ញុំប្ដេជ្ញាចិត្តដើម្បីសុវត្ថិភាព៖

- **ខ្ញុំមាន**លិខិតអនុញ្ញាតធ្វើការងារ និងវិញ្ញាបនបត្រជីកកាយ
- **ខ្ញុំបញ្ជាក់ថា** ទីកន្លែងជីកកាយត្រូវដាក់សញ្ញាហាមឃាត់ច្បាស់
- **ខ្ញុំប្រុងប្រយ័ត្ន**ចំពោះទីតាំងដែលមានបណ្ដាញក្រោមដី និងគ្រឿងបង្កំនានា
- **ខ្ញុំដាក់ម៉ាស៊ីន** និងសម្ភារកាយចេញយ៉ាងហោចណាស់មួយម៉ែត្រពីកន្លែងជីកកាយ
- **ខ្ញុំចូលតែកន្លែង**ជីកកាយដែលមានជម្រៅជាង ១,៣ ម៉ែត្រ ប្រសិនបើការចូលទៅត្រូវបានធានាសុវត្ថិភាព។

Rule **10**

# ការងារនៅទីខ្ពស់



ខ្ញុំការពារខ្លួនកុំឱ្យធ្លាក់ នៅពេលធ្វើការនៅ
កម្ពស់ ≥ ១.៥ ម៉ែត្រ

ខ្ញុំប្ដេជ្ញាចិត្តដើម្បីសុវត្ថិភាព៖

- **ខ្ញុំពិនិត្យ**ខ្សែក្រវាត់សុវត្ថិភាព ខ្សែយោង និងខ្សែថ្លក់យួរមុនពេលប្រើប្រាស់
- **ខ្ញុំការពារ**ឧបករណ៍ និងសម្ភារនានាកុំឲ្យ ធ្លាក់ចុះ
- **ខ្ញុំពាក់**ខ្សែក្រវាត់សុវត្ថិភាព និងចងឲ្យនឹងជាមួយចំនុចលំនឹងដែលអនុម័តស្របតាមលិខិតអនុញ្ញាតការងារ
- **ខ្ញុំប្រើ**រន្ទាត្រូវនឹងគោលបំណង និងត្រូវបានអនុម័ត
- **ខ្ញុំគោរព**គម្លាតសុវត្ថិភាពអប្បបរមានៅពេលធ្វើការនៅជិតខ្សែបណ្ដាញថាមពល
- **ខ្ញុំធានា**លក្ខណៈរឹងមាំនៃដំបូល (ធុងស្តុក អាគារ ពិដាន ...) មុនពេលការងារចាប់ផ្តើមនិងដំឡើងឧបការណ៍ដែលការពារការធ្លាក់សម្រាប់ទីតាំងដែលមានភាពផុយស្រួយ
- **ខ្ញុំបំលាស់**ទីម៉ាស៊ីនស្ទូចចល័ត (MEWP) ក្នុងស្ថានភាពផ្ទៃទាបតែប៉ុណ្ណោះ។

## Rule 11

# ការងារក្តៅ

ខ្ញុំចៀសវាងធ្វើការងារក្តៅតាមដែរអាចធ្វើបាន

ខ្ញុំប្តេជ្ញាចិត្តដើម្បីសុវត្ថិភាព៖

- ☑ **ខ្ញុំមាន**លិខិតអនុញ្ញាតធ្វើការងារក្តៅ
- ☑ **ខ្ញុំដឹង**ពីសារធាតុងាយឆាបឆេះ និងប្រភពចំហេះ។
- ☑ មុនពេលចាប់ផ្តើមការងារក្តៅ៖
  - ខ្ញុំធានានូវអវត្តមានសារធាតុងាយឆាបឆេះ ឬដកចេញសារធាតុទាំងនោះចេញ
  - ខ្ញុំទទួលបានការអនុញ្ញាតជាលាយលក្ខណ៍អក្សរ
- ☑ នៅកន្លែងដែលគ្រោះថ្នាក់ ខ្ញុំបញ្ជាក់ថា៖
  - បានធ្វើតេស្តអវត្តមានឧស្ម័នហ្គាស
  - ត្រួតពិនិត្យជាប្រចាំនូវអវត្តមានឧស្ម័នហ្គាស។

## Rule 12

# គន្លងគ្រោះថ្នាក់

ខ្ញុំឱ្យខ្លួនឯង និងអ្នកដទៃស្ថិតនៅក្រៅគន្លងគ្រោះថ្នាក់

ខ្ញុំប្តេជ្ញាចិត្តដើម្បីសុវត្ថិភាព៖

- ☑ ខ្ញុំដាក់ខ្លួនឯងឱ្យនៅទីតាំងមួយដើម្បីចៀសវាង៖
  - បំលាស់ទីវត្ថុ
  - យានយន្ត
  - ការបញ្ចេញសម្ពាធ
  - វត្ថុធ្លាក់ចុះ
- ☑ ខ្ញុំបង្កើតរនាំង និងតំបន់ហាមឃាត់
- ☑ ខ្ញុំចាត់វិធានការ ដើម្បីធានាឱ្យមានសុវត្ថិភាពវត្ថុដែលមិនបានការពារល្អ
- ☑ ខ្ញុំគោរពរនាំង និងតំបន់ហាមឃាត់។

# ការប្រើ STOP CARD
# គឺការចាត់វិធានការដើម្បីសុវត្ថិភាព

**យើងមានកាតព្វកិច្ចក្នុងការអន្តរាគមន៍ភ្លាមៗនៅពេលដែលស្ថានភាពមើលទៅអាចមានគ្រោះថ្នាក់ចំពោះយើង និងនៅពេលGolden Rules មិនត្រូវបានអនុវត្ត។**

ទោះបីនៅពេលសង្ស័យក៏ដោយ ត្រូវប្រើ STOP CARD ដោយមិនភ័យខ្លាចពីការដាក់ទណ្ឌកម្ម!

តាមរយៈការសួរសំណួរអំពីសុវត្ថិភាពនៃសកម្មភាព និងបញ្ឈប់ការងារដែលកំពុងដំណើរការ យើងអាចទប់ស្កាត់គ្រោះថ្នាក់ និងជួយសង្គ្រោះអាយុជីវិត។



TotalEnergies

**Health, Safety,**
**Environment Division**
**TotalEnergies SE**

2 place Jean Millier
92400 Courbevoie - France
Tel.: +33 (0)1 47 44 45 46

Share capital:
6,601,073,322.50 euros
542 051 180 RCS Nanterre

totalenergies.com

THE 12 GOLDEN RULES
PUBLISHED IN JANUARY 2022